សកម្មភាព ៖ **ល្បែងតម្បាញ**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែក សាច់ដុំភ្នែក)។

**សិក្សាសង្គម**

ការលើកតម្កើនវប្បធម៌សង្គម(ការលើកតម្កើនវប្បធម៌របស់ខ្លួន)

គំនូរ និងសកម្មភាពកសាង(ការយល់ដឹងអំពីការឆ្លាស់វត្ថុ តាមចង្វាក់ និងការគូរគំនូរ)

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីររបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬ លេងល្បែង។

អំណត់ ព្យាយាម ស្វាហាប់ រហ័សរហួន និងសប្បាយរីករាយ។

ធ្វើចលនាម្រាមដៃដោយទប់ លំនឹងតាមទម្រង់ផ្សេងៗនៃ សកម្មភាពណាមួយ។

**(សិក្សាសង្គម)** ប្រាប់បានពីឈ្មោះបុណ្យប្រពៃណីជាតិខ្មែរ  ដូចជាភ្ជុំបិណ្ឌ បុណ្យចូលឆ្នាំប្រពៃណីខ្មែរប្រាប់បានពីសម្លៀកបំពាក់ប្រពៃណីជាតិខ្មែរ ដូចជាក្រមា ហូល  ផាមួង អាវប៉ាក់ជាដើម។ ប្រាប់បានពីរបៀបដោតអង្កាំ ឬ វត្ថុផ្សេងៗដែលមានប្រហោងសម្រាប់ដោតឆ្លាសពណ៌តាមរូបគំរូ និងគូសគំនូសផ្សេងៗជាដើម។  សប្បាយរីករាយ  និងចូលចិត្តធ្វើសកម្មភាពដោយងាយៗខ្លួនឯង។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "កុមារគំរូ "

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ អំបោះ ក្រដាសកេះ ម្ជុលជ័រ ឬដង្កៀបខ្មៅ និងខ្សែលីឡុងសម្រាប់ធ្វើជាកីតម្បាញ។

**ការរៀបចំ** ៖ ត្រូវរៀបចំជាកីតម្បាញជាមុនសិនទុកបង្ហាញក្មេងៗ។

**សេចក្តីណែនាំ៖**

1. ប្រាប់ក្មេងៗថា ថ្ងៃនេះអ្នកគ្រូនឹងលេងល្បែង តម្បាញ ជាមួយកូនៗទាំងអស់គ្នា។
2. បង្ហាញ‹ក្រមា› ហើយសួរថា កូនៗតើនេះជាអ្វី?
3. សរសេរពាក្យថា ‹ក្រមា› នៅលើក្តារខៀន។

4. អ្នកសួរក្មេងៗថា តើគេប្រើក្រមានៅពេលណា?
   - នៅពេលបុណ្យប្រពៃណីជាតិខ្មែរ ចូលឆ្នាំខ្មែរ ភ្ជុំបិណ្ឌ។
5. សួរសំណួរមួយទៀតថា តើក្រមាមានសារៈសំខាន់អ្វីខ្លះ?
   - ចាស/បាទ ជូតខ្លួន ដើម្បីងូតទឹក ជូតមុខ ពានាទៅវត្ត ទទួលបាំងថ្ងៃ ។
6. និយាយប្រាប់ក្មេងៗពីប្រវត្តិក្រមា មានចាប់ តាំង ពីសតវត្ស ទីមួយនៃរជ្ជកាលព្រះបាត ហ៊ុន ទៀន (Hun Tean) ។
7. ហេប្រាប់ក្មេងៗថា តុអ្វីបានជាគេប្រើក្រមារហូតមកដល់សព្វថ្ងៃ ។
   - ពីព្រោះក្រមា បានក្លាយ ជាអត្តសញ្ញាណ នៃសម្លៀក បំពាក់ ខ្មែរ។
8. សួរពួកគេថា ដឹងពីរបៀបធ្វើវាដែរអត់? - បាទ/ចាស មិនដឹង ដឹង
9. សរសេរពាក្យ ត្បាញ ឬតម្បាញ នៅលើក្ដារខៀន និងពន្យល់ពាក្យទាំង២ទៅក្មេងៗឱ្យច្បាស់។
   - ➔ តម្បាញ គឺជាគ្រឿងប្រដាប់សម្រាប់ត្បាញ
   - ➔ ត្បាញ គឺខ្វាស់ចេសអំបោះ ឬចេសសូត្រឱ្យក្លាយជាក្រមា ឬសំពត់
10. បង្ហាញក្មេងៗពី ‹កីតម្បាញ› ដែលអ្នកបានធ្វើទុករួចនោះទៅកាន់ក្មេងៗ។
11. បង្ហាញក្មេងៗពីរបៀបធ្វើ និងចងកីតម្បាញ ជាមួយនឹងអំបោះ។
12. បន្ទាប់មក បង្ហាញក្មេងៗពីរបៀបនៃការត្បាញដែលយើងត្រូវ ប្រើម្ជុលជ័រ ឬ ដង្កៀបខ្មៅ។
13. ចាប់ផ្ដើមចែកសម្ភារឱ្យទៅកាន់ក្មេងៗ និងជួយពួកគេ ប្រសិនបើពួកគេត្រូវការជំនួយពីអ្នក។
14. បង្ហាញពួកគេពីរបៀបនៃការចងខ្សែរអំបោះនៅពេលដែលត្បាញរួចរាល់។
15. ចុងក្រោយ ពួកគេអាចដោះវាចេញពីលីតម្បាញហ្នឹងបានជាការស្រេច។

របៀបធ្វើកីតម្បាញ

- ត្រូវត្រៀមសម្ភារ ដូចជា៖ ក្រដាសកេះដែលមានរាងចតុកោណកែង អំបោះដែលមានពណ៌ផ្សេងៗពីគ្នាទៅតាមការចូលចិត្តរបស់អ្នក ម្ជុលជ័រ ឬដង្កៀបខ្មៅ និងខ្សែលីឡុងសម្រាប់ធ្វើជាកីតម្បាញ។
- ដំបូង យកក្រដាសកេះដែលមានរាងចតុកោណកែង កាត់ខាងចុងបន្តិចជាចម្រៀកៗស្មើៗគ្នា ទាំងសងខាង សម្រាប់ខ្វាស់អំបោះ។

- នៅពេលដែលចងខ្សែរួចហើយនោះ ចាប់ផ្តើមប្រើអំបោះដែលមានច្រើនពណ៌នោះ ត្បាញជាក្រមា ទៅតាមការចូលចិត្តរបស់ពួកគេ។ ការត្បាញធ្វើដូចជាត្បាញកន្ទេលអញ្ចឹងដែរណា។ រុំព័ទ្ធ និងសូក លើក្រោមទៅវិញទៅមកជាក្រឡា និងលាយពណ៌អំបោះ ដើម្បីឱ្យវាកាន់តែស្រស់ស្អាតជាមុនទៀត។